# គំនូរយានសាងផ្នួស

## ១- ព័ត៌មានទូទៅ

ទំនៀមតាមតំបន់ក្នុងប្រទេសកម្ពុជា នៅបន្តរក្សារបៀបទេសនាមើលសាស្ត្រាដែលមានអត្ថបទធម៌បុរាណជាច្រើនប្រភេទ និងតម្រូវទៅតាមកម្មវិធីបុណ្យ។ ក្នុងបណ្ដាបុណ្យទាំងនោះនៅក្នុងពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌវត្តមួយចំនួន តែងលើកយកមហាជាតក៍មកទេសន៍ចាប់ពីកណ្ឌទីមួយកំណត់នៅបិណ្ឌមួយ រហូតដល់កណ្ឌទីដប់បី បិណ្ឌដប់បីនិងជាលីកិសេកនៅថ្ងៃបន្តបន្ទាប់។ វត្តដទៃទៀតក៏និយមទេសន៍រឿងផ្សេងពីនោះគឺទេសន៍សាស្ត្រាបឋមសម្ពោធិ៍តាមទម្លាប់ពីដូនតាក្នុងតំបន់នោះ។ មូលហេតុដែលគេយកអត្ថបទធម៌ទាំងនេះមកទេសន៍ព្រោះអត្ថបទធម៌មានទំហំវែង ហើយដំណើររឿងប្រទាក់ក្រឡាគ្នាគួរឱ្យចង់ស្ដាប់មិនជិនណាយ ស្របជាមួយនឹងរយៈពេលប្រារព្ធបុណ្យដែលមានរយៈដប់ប្រាំថ្ងៃ។សាស្ត្រាបឋមសម្ពោធិ៍ជាគម្ពីរសម្ដែងរៀបរាប់ពីពុទ្ធដំណើរ ចាប់ពីព្រះអង្គបដិសន្ធិរហូតទល់គ្នានឹងចែកព្រះបរមធាតុ(រូបលេខ១ ២)។[១]



រូបលេខ១បឋមសម្ពោធិ៍ពជាកិសេកបរិច្ឆេទទី១ខ្សែ៥ប្រភព៖Khmermanuscripts.efeo.fr



រូបលេខ២ មហាជាតក៍ កណ្ឌឆក្សត្រ ប្រភព៖Khmermanuscripts.efeo.fr

ដំណើររឿងរ៉ាវទាំងនោះក៏បានស្ដែងជាសិល្បៈគំនូរម្យ៉ាងដែលយើងហៅថា គំនូរពុទ្ធប្បវត្តិ យ៉ាងសម្បូរបែបនៅតាមបណ្ដាវត្តទូទាំងប្រទេសកម្ពុជា។ គំនូរពុទ្ធប្បវត្តិជាសិល្បៈមួយប្រភេទដែលខ្មែរនិយមគូរនៅទីសក្ការៈសាសនាដូចជា៖ ព្រះវិហារ សាលាធម្មសភា សាលាឆាន់ សាលាឆទាន សាលាបុណ្យ។ ចំពោះរូបដែលគេគូរគឺគិតទៅតាមទីតាំង

[១] ចំពោះចំនួនបរិច្ឆេទច្បាប់ខ្លះមាន៣០បរិច្ឆេទ ច្បាប់ខ្លះទៀតមាន៣១បរិច្ឆេទ។

ដាក់ស្ដែង តើគេអាចគូរបានច្រើនវត្តដែលឬទេ? អ្វីដែលយើងកត់សម្គាល់ឃើញជាទូទៅ គំនូរនៅតាមព្រះវិហារមានគំនូរពីរប្រភេទ គឺគំនូរបឋមសម្ពោធ(គូរផ្នែកខាងលើ) និងគំនូរទសជាតក៏(គូរផ្នែកខាងក្រោម) (រូបលេខ៣)។



រូបលេខ៣គំនូរក្នុងព្រះវិហារវត្តជ្រោយតាកែវ ខេត្តណ្ដាល ខាងលើជាគំនូរបឋមសម្ពោធិ៏ត្រង់ពួកមល្លក្សត្ររៀបចំថ្វាយព្រះភ្លើងព្រះបរមសព្វព្រះសម្មសម្ពុទ្ធនៅឯនគរកុសិនារា។ ខាងក្រោមជាគំនូរទសជាតក៏ ខាងឆ្វេងជាកណ្ឌទសពរក្នុងរឿងព្រះវេស្សន្តរ ខាងស្ដាំជារឿងព្រះតេមិយជាតកចាប់ពីដើមដល់ចប់។

គំនូរទាំងអស់នេះគូរយោងទៅតាមគម្ពីរជាតក ដែលខ្មែរធ្លាប់បានសិក្សារៀនសូត្រយល់ដឹងពីមុនមក ទើបធ្វើឱ្យដំណើររឿងក្នុងគំនូរ ដូចក្នុងគម្ពីរ។

### ក.លក្ខណៈទូទៅនៃគំនូរយាងសាងព្រះផ្នួស

នៅក្នុងគម្ពីរបឋមសម្ពោធិ៏ អភិនេស្រ្កម៏បរិច្ឆេទ ជាសេចក្ដីបរិយាយអំពីកាលព្រះសិទ្ធត្ថស្ដេចយាងចេញសាងព្រះផ្នួស។ បន្ទាប់ពីរាជអាមាត្យទូលដំណឹងថាបុត្រព្រះអង្គ

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ប្រសូតមកហើយ ព្រះទ័យរបស់ព្រះសិទ្ធត្ថកុមារក៏នឹកនឿយណាយក្នុងជីវិតជាយរាវាស ហើយទ្រង់បានសម្រេចព្រះទ័យយាងចេញសាងព្រះផ្នួសក្នុងរាត្រីនោះតែម្តង។ ប៉ុន្តែមុននឹងចេញពីព្រះបរមរាជវាំងទ្រង់ទតនាងពិម្ពា និងបុត្រដែលទើបនឹងប្រសូត ជាលើកចុងក្រោយ។ នៅត្រង់នេះសិល្បៈគំនូរបានយកសេចក្តីនេះមកបរិយាយជារូបភាពបង្ហាញពីសភាពរបស់ពួកស្រីស្នំ ពួកស្រីរបាំ ដែលច្រៀង លេងភ្លេង និងរាំថ្វាយព្រះសិទ្ធត្ថទត រូបស្រីស្នំ ស្រីរបាំបានដេកលង់លក់ដោយសភាពផ្សេង អ្នកខ្លះកាយអាក្រាត របូតសំពត់ហៀរទឹកមាត់។ ដើម្បីស្តែងឱ្យឃើញដូចគ្នាទៅនឹងដំណើររឿងក្នុងគម្ពីរគេត្រូវបង្ហាញដងខ្លួនមនុស្សស្រីដេកអាក្រាតកាយ អ្នកខ្លះទៀតមានស្បែស្តើងៗដណ្តប់ហើយចេញកេរខ្មាស ខ្លះទៀតមានស្បែដណ្តប់ពីលើប៉ុន្តែបង្ហាញកេរខ្មាសជាហេតុៗ(រូបលេខ៤ដល់៧)។[២]



រូបលេខ៤ គំនូរវត្តស្វាយខ្សាច់ភ្នំ

[២] សូមអានៈ គណៈកម្មការធម្មវិន័យ, ពុទ្ធប្បវត្តិភាគ២ អរិទូរេនិទាន, ភ្នំពេញ, ឆ្នាំ១៩៤១

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ២៥ គំនូរវត្តតាំងវនាម



រូបលេខ២៦ គំនូរវត្តសំរិទ្ធជ័យារាម

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ២៧ គំនូរវត្តបាគង

គំនូរបែបនេះចំពោះក្មេកមនុស្សបច្ចុប្បន្នមើលហើយ បែរគិតថាហាក់ដូចជារឿងមិនសមរម្យ អាសអាភាស ធ្វើឱ្យអ្នកមើលហើយវិលវល់ក្នុងគំនិតស្រើបស្រាល លិចលង់ក្នុងចំណងកាមគុណ។ ស្ថិតក្នុងគំនិតដដែលនេះវត្តមួយចំនួនបានកែគំនូរត្រង់វគ្គនេះ ដោយគូរសំពត់អាវ គ្រប់ពីលើមនុស្សស្រីទាំងនោះ។ ចួនកាលកោសលុបកន្លែងនោះចោលតែម្តងដើម្បីកុំឱ្យឃើញរូបអាក្រាតទាំងនោះតទៅទៀត(រូបលេខ២៨ ៩)។



រូបលេខ២៨ គំនូរវត្តឥន្ទមូលី

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ៩ គំនូរវត្តបញ្ចកែវមុនី

**២.សេចក្ដីសម្រង់ក្នុងឯកសារផ្សេងៗ**

ដូចបានជម្រាបមកខាងលើហើយថាគំនូរទាំងនោះមិនមែនចេញពីការប្រឌិតឬ ទៅតាមការនឹកឃើញនោះទេគឺជាងគំនូរគូរយោលទៅតាមគម្ពីរបឋមសម្ពោធិ៍ ដែលជាគម្ពីរដើមនៃដំណើររឿងពុទ្ធប្បវត្តិ។ខាងក្រោមនេះជាសម្រង់សាស្ត្រាបឋមសម្ពោធិ៍ មហាអភិស្សក្រុំមបរិច្ឆេទទី៦



ប្រភព៖Khmermanuscripts.efeo.fr

សន្ទឹកលេខ២៧៨ ....ទ្រង់ព្រះចិន្តាដូច្នោះទ្រង់ដោះនូវកែមុក្តាអំពីព្រះសូរងទ្រង់ឱ្យយកទៅថ្វាយព្រះនាង ហើយព្រះអង្គស្ដេចចូលទៅកាន់ប្រាសាទគង់លើព្រះផែនអាសនៈ

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

រាជបល្ល័ង្ក ព្រមដោយនាងស្នំច្រៀងរាំប្រគុំថ្វាយព្រមៗគ្នាព្រះអង្គទ្រង់និទ្រាផ្ទំលក់ស្កប់ស្កល់ក្នុងបឋមយាម បពិត្រអើយលំដាប់នោះទេវតាក៏បណ្ដាលឱ្យនាងរបាំព្រះស្នំដេកលក់អស់...



ប្រភព៖Khmermanuscripts.efeo.fr

សន្ទឹកលេខ៧៩ សម្ដែងនូវអាការគឺវិបរិតផ្សេងៗនាងខ្វះដេកស្រមុ៉ក នាងខ្វះដេកថ្ងូរនាងខ្វះដេកមមើមមាយនាងខ្វះមានសំពត់នូវអាវស្បៃអាក្រាតពីខ្លួន នាងខ្វះដេកហូរទឹកមាត់ទឹកសម្បោរ នាងខ្វះដេកប្រគងលើគ្នានឹងគ្នាមានកិរិយាមិនគួរជាទីទស្សនា បពោធិសិត្វា(?) ព្រះពោធិសម្ភារទ្រង់តើនើងមុនគង់លើព្រះថៃនឈ្នៀងនេត្រាទតឃើញស្រីទាំងឡាយមានអាការផ្សេងៗដូច្នោះក៏ទ្រង់ពិចារណាឃើញថាបីដូចជាអសុភ ទើបព្រះអង្គទ្រង់ប្រារព្ធថាយើងនេះមកដេកក្នុងបច្ឆា ហើយទ្រង់តម្រិះថាមិនសមគួរដែលយើងនឹងវង្វេងនៅក្នុងគំនរលាមកគួរតែប្រាថ្នារកសេចក្ដីសុខទើបរួចខ្លួន....។

ក្រៅពីនេះក៏មានសេចក្ដីពន្យល់ក្នុងសៀវភៅពុទ្ធប្បវត្តិអវិទូរេនិទានថា៖ ព្រះបរមពោធិសត្វទ្រង់ស្ដេចឡើងលើប្រាសាទដោយព្រះក្រយាស្នោយស្រេចហើយទ្រង់ស្ដេចចូលទៅកាន់ទីសយនាក្រឡាព្រះបន្ទំទ្រង់ផ្ទំលក់ស្កប់ស្កល់ក្នុងពេលបឋមយាម។ ចំណែកខាងពួកស្រីរបាំសុទ្ធតែប្រដាប់តាក់តែងរាងកាយដោយគ្រឿងអលង្ការគ្រប់បែបយ៉ាង ទាំងរូបឆោមលោមពណ៌ ក៏ស្រស់ឆើតឆាយហាក់ដូចទេពកញ្ញាក្នុងឋានទេវលោកដែលជាអ្នកស្ទាត់ក្នុងល្បែងច្រៀងរាំជាដើម នាំគ្នាប្រគុំតូរ្យតន្ត្រីច្រៀងរាំថ្វាយព្រះមហាសត្វ។ ស្រីរបាំទាំងនោះ លុះដឹងថាព្រះមហាបុរសទ្រង់ផ្ទំស្កប់ស៊ប់ហើយក៏នាំបញ្ឈប់គ្រឿងល្បែងហើយដេកលក់អស់ទៅសម្ដែងវិប្បការៈផ្សេងៗមាន ស្រីខ្វះដេកហាមាត់ ខ្វះដេករបូតសំពត់ចេញពីខ្លួនជាដើម។ លុះដល់ពេលមជ្ឈិមយាមព្រះពោធិសត្វទ្រង់តើនឡើងហើយទត

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ឃើញវិប្បការៈនៃស្រីទាំងនោះ ក៏មានព្រះរាជហឫទ័យសង្វេគនឿយណាយយ៉ាងខ្លាំង ព្រោះឃើញទីប្រាសាទទាំងមូល ហាក់ដូចជាពាសពេញទៅដោយសាកសពដែលគួរឱ្យខ្ពើមរអើមជាទីបំផុតព្រះទ័យព្រះអង្គទោរទន់ទៅក្នុងភេទបព្វជ្ជារឹងរឹតតែមាំមួនឡើងៗ[៣]

សេចក្តីបរិយាយក្នុង ព្រះត្រៃបិដក និងអដ្ឋកថាជាតកពន្យល់ថា៖ ព្រះពោធិសត្វមានបរិវារហែមហមយ៉ាងច្រើនទ្រង់យាងចូលក្នុងនគរវិញ។ ទ្រង់ឡើងកាន់ប្រាសាទដ៏មានសិរីទ្រង់នឿយណាយក្នុងគ្រឿងអលង្ការគ្រប់ប្រភេទ មិនមានចិត្តត្រេកអរក្នុងរបាំទាំងឡាយហើយក៏ចូលកាន់និទ្រាផ្ទំលក់មួយភ្លែតទៅ។ ស្រីរបាំទាំងឡាយឃើញព្រះពោធិសត្វផ្ទំលក់ក៏គិតថា៖ តើយើងនាំលេងរបាំដើម្បីអ្នកណាទៀត បើព្រះអយ្យបុត្រផ្ទំលក់ហើយនោះ។ ស្នំទាំងឡាយក៏នាំគ្នាពន្លត់ភ្លើងហើយដេកលក់ទាំងអស់គ្នាទៅ។ កាលព្រះពោធិសត្វភ្ញាក់រលឹកឡើងទ្រង់អង្គុយពែនភ្នែនលើសេយ្យាសនា សំឡឹងទៅមើលស្រីរបាំទាំងនោះដែលមានអាការដូចសាកសព ស្រីខ្លះដេកហៀរទឹកមាត់ ខ្លះទៀតគគាតធ្មេញ ខ្លះដេកចំហមាត់ ខ្លះដេកផ្កាប់មុខ ខ្លះដេករបូតសំពត់។ កាលព្រះពោធិសត្វឃើញយ៉ាងនោះក៏នឿយណាយក្នុងបញ្ចកាមគុណ មានបំណងចេញសាងផ្នួសស្វែងរកមោក្ខធម៌ដែលនាំឱ្យផុតជាតិជរាព្យាធិនិងមរណៈ...។[៤]

បើយើងប្រៀបធៀបសេចក្តីសម្រង់ទាំងបីខាងទៅនឹងគំនូរនៅតាមព្រះវិហារ មានសេចក្តីដូចគ្នាព្រោះគំនូរក្តី ដំណើររឿងក្នុងគម្ពីរក្តី សុទ្ធតែចង់បរិយាឱ្យឃើញពីទិដ្ឋភាពផ្សេងៗក្នុងពុទ្ធប្បវត្តិដើម្បីបង្ហាញពីភាពអស្ចារ្យរបស់ព្រះពោធិសត្វ ដែលទ្រង់អាចកាត់ព្រះហឫទ័យសាងព្រះផ្នួសចោលមហេសីប្រកបដោយលក្ខិណាសម្បត្តិលើសស្រីទាំងពួងនិងបុត្រជាទីស្រឡាញ់ទើបតែប្រសូត្រក្នុងថ្ងៃនោះ។ ជាពិសេសបញ្ចកាមគុណជាទីត្រេកត្រអាលនៃបុរសដែលមានស្រីស្នំ ស្រីរបាំរូបស្អាតៗយ៉ាងល្អក្រៃលែងកម្រនឹងបុរសណា

[៣] គណៈកម្មការធម្មវិន័យ, ពុទ្ធប្បវត្តិភាគ២ អវិទូរេនិទាន, ភ្នំពេញ, ឆ្នាំ១៩៩៥១, ទំ.១៩

[៤] កុល ផេង, មាគ៌ាជីវិតនៃព្រះពោធិសត្វ, ភ្នំពេញ, ឆ្នាំ២០០៩, ទំ.១៥៧

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

មួយលះបង់បានមានចិត្តសំឡឹងត្រង់ភ្លោះត្រង់នេក្ខម្ម ឃើញស្រីទាំងដោយវិវេគធម៌ឃើញជាសាកសពមានចិត្តចង់ទៅបួសចោលស្រីស្នំស្រីរបាំដែលធ្លាប់បម្រើកាមគុណគ្មានទើសទាល់រាល់ពេលវេលា។ ត្រង់ចំណុចនេះហើយដែលអ្នកប្រាជ្ញបុរាណតែងពោលថាទ្រង់បំពេញនូវមហាអភិនេស្រ្កម៍។

សរុបមកវិញគំនូរទ្រង់យាងចេញសាងព្រះផ្នួសដែលយើងឃើញនៅតាមកុដិ សាលា ព្រះវិហារ កន្លែងសក្ការៈគ្រប់កន្លែងនោះសុទ្ធតែជាការគូរបង្ហាញឱ្យឃើញពីចំណេះផ្នែកព្រះពុទ្ធសាសនារបស់វិចិត្រករ ក៏ដូចជាអ្នកដឹកនាំកសាង ដែលមិនមែនជារឿងអាសអាភាសដូចតែគំនិតមនុស្សបច្ចុប្បន្នគិតឡើយ។

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយៈ រឹម ទិត្យបញ្ញា

## ឯកសារពិគ្រោះ

កុល ផេង

២០០៩ មាគ៌ាជីវិតនៃព្រះពោធិសត្វ ភ្នំពេញ

គណៈកម្មការធម្មវិន័យ

១៩៥១ ពុទ្ធប្បវត្តិភាគ១ ទូរេនិទាន ភ្នំពេញ

១៩៥១ ពុទ្ធប្បវត្តិភាគ២ អវិទូរេនិទាន, ភ្នំពេញ

២០០២ ពុទ្ធប្បវត្តិភាគ៣ សន្តិកេនិទាន, ភ្នំពេញ

សាស្ត្រាបឋមសម្ពោធិ៍

សាស្ត្រាមហាជាតក៍

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION